**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងអប់រំ យុវជន និងកីឡា**

## សេចក្តីប្រកាសព័ត៌មាន

ក្រសួងអប់រំ យុវជន និងកីឡានៃព្រះរាជាណាចក្រកម្ពុជា នឹងរៀបចំវេទិកាសកលស្តីពីអាហារូបត្ថម្ភកុមារ លើកទី ២១ ដែលនឹងប្រព្រឹត្តទៅចាប់ពីថ្ងៃទី២ ដល់ទី៦ ខែធ្នូ ឆ្នាំ២០១៩ នៅសណ្ឋាគារអេប្សារាផាលែសនិងរីសត ខេត្តសៀមរាប ដោយសហការជាមួយ Global Child Nutrition Foundation (GCNF) និង World Food Programme Centre of Excellence against Hunger (WFP CoE)។ វេទិកាសកលនេះមានការអញ្ជើញចូលរួមពីថ្នាក់ដឹកនាំរដ្ឋាភិបាល រដ្ឋមន្ត្រី និងមន្ត្រីអប់រំក៏ដូចជាអ្នករៀបចំគោលនយោបាយ អ្នកអនុវត្តគោលនយោបាយ អ្នកស្រាវជ្រាវ និងដៃគូអភិវឌ្ឍ មកពីប្រទេសចំនួន ៦០ និងអ្នកចូលរួមចំនួន ៣៨០ នាក់។ **ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ** ជាតំណាងដ៏ខ្ពង់ខ្ពស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា** នឹងចូលរួមជាអធិបតីក្នុងពិធីបើក។

វេទិកាសកលស្តីពីអាហារូបត្ថម្ភកុមារលើកទី២១ ត្រូវបានរៀបចំឡើង ដើម្បីជាវេទិកាចែករំលែកបទពិសោធន៍ក្នុងការអនុវត្ត បញ្ហាប្រឈម និងឧត្តមានុវត្តនៃកម្មវិធីផ្តល់អាហារនៅសាលារៀន។ វេទិកានៅឆ្នាំ២០១៩នេះ ជាកាលានុវត្តភាពមួយសម្រាប់ប្រទេសដែលបានចូលរួមអាចផ្តោតការយកចិត្តទុកដាក់លើបទពិសោធន៍នៃការអនុវត្តកម្មវិធីផ្តល់អាហារនៅសាលារៀន ក្នុងការពង្រឹងប្រសិទ្ធភាពនៃការអនុវត្ត ការបង្កើនភាពជាម្ចាស់នៃប្រទេសលើហិរញ្ញប្បទាន និងការប្រតិស្ឋានកម្មវិធីនេះនៅក្នុងប្រព័ន្ធអប់រំជាតិ និងការគាំពារសង្គម ប្រកបដោយគោលនយោបាយស៊ីជម្រៅ បរិយាបន្ន និងនិរន្តរភាព។

កម្មវិធីផ្តល់អាហារនៅសាលារៀន គឺជាការផ្តល់លាភការជាអាហារ ដែលផ្តល់អត្ថប្រយោជន៍ផ្នែកអប់រំ អាហារូបត្ថម្ភ និងសុខភាពដល់កុមារនៅតាមសាលារៀន។ កម្មវិធីនេះបានចូលរួមដល់ការលើកកម្ពស់ការចុះឈ្មោះចូលរៀន ការកាត់បន្ថយអវត្តមាន និងការធ្វើឲ្យប្រសើរឡើងនូវសន្តិសុខស្បៀង។ វេទិកាសកលស្តីពីអាហារូបត្ថម្ភកុមារ គឺជាវេទិកាប្រចាំឆ្នាំដែលធំជាងគេបំផុត ស្តីពីការផ្តល់អាហារនៅសាលារៀននៅលើពិភពលោក។ មកទល់ឆ្នាំ២០១៩នេះ វេទិកាសកលស្តីពីអាហារូបត្ថម្ភកុមារ ត្រូវបានប្រារព្ធឡើងចំនួន ២១ លើក និងជាលើកទី១ ដែលវេទិកានេះត្រូវបានប្រារព្ធឡើងនៅទ្វីបអាស៊ី និងនៅព្រះរាជាណាចក្រកម្ពុជា។

ជាព័ត៌មានបន្ថែម ក្រសួងអប់រំ យុវជន និងកីឡាសូមបញ្ជាក់ថា ក្នុងឆ្នាំសិក្សា ២០១៨-២០១៩ នៅព្រះរាជាណាចក្រកម្ពុជា ដោយមានការគាំទ្រពីសំណាក់កម្មវិធីស្បៀងអាហារពិភពលោកនៃអង្គការសហប្រជាជាតិ និងដៃគូអភិវឌ្ឍមួយចំនួន កម្មវិធីផ្តល់អាហារនៅសាលារៀនត្រូវបានអនុវត្តនៅតាមសាលាបឋមសិក្សាចំនួន ១១៦៧ នៅក្នុងខេត្តចំនួន ៨ និងមានកុមារចំនួន ២៦ ម៉ឺននាក់ បានទទួលរបបអាហារពេលព្រឹក កុមារប្រមាណ ៨ ពាន់នាក់ទទួលរបបអាហារូបករណ៍ជាស្បៀង និងប្រមាណ ៥ ម៉ឺននាក់ទៀតទទួលរបបអាហារពេលព្រឹកដែលប្រើប្រាស់កសិផលសហគមន៍។ នៅឆ្នាំ ២០១៩ ដោយទទួលបានថវិកាបន្ថែមពីសំណាក់រាជរដ្ឋាភិបាលកម្ពុជា កម្មវិធីផ្តល់អាហារនៅសាលារៀននឹងពង្រីកវិសាលភាពនៅតាមខេត្តចំនួន៦បន្ថែមទៀត ដែលគ្របដណ្តប់បន្ថែមលើសាលាបឋមសិក្សាចំនួន ២០៥ និងមានកុមារប្រមាណ ៥ ម៉ឺននាក់បានទទួលផល។ ការបង្កើនវិសាលភាពនេះ ធ្វើឱ្យបរិមាណអង្ករ ដែលត្រូវប្រើប្រាស់ក្នុងកម្មវិធីផ្តល់អាហារនៅសាលារៀននឹងកើនដល់ជិត ៨ ពាន់តោន ដែលក្នុងនោះអង្ករជាង ២៥០០ តោន និងបន្លែជិត ៨០០ តោន នឹងត្រូវទិញដោយផ្ទាល់ពីសហគមន៍។

កម្មវិធីផ្តល់អាហារនៅសាលារៀន ជាអាទិភាពដ៏ចម្បង ដូចមានចែងក្នុងផែនការយុទ្ធសាស្រ្តអប់រំ ២០១៩-២០២៣ និងក្នុងគោលនយោបាយជាតិស្តីពីកិច្ចគាំពារសង្គម ព្រមទាំងជាមូលដ្ឋាននៃការកសាងមូលធនមនុស្សនៃព្រះរាជាណាចក្រកម្ពុជា ។

អាស្រ័យហេតុនេះ សូមសាធារណជនមេត្តាជ្រាបជាព័ត៌មាន។៚

ថ្ងៃសុក្រ ៣កើត ខែមិគសិរ ឆ្នាំកុរ ឯកស័ក ព.ស. ២៥៦៣
រាជធានីភ្នំពេញ ថ្ងៃទី២៩ ខែវិច្ឆិកា ឆ្នាំ២០១៩